# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ខេត្តសៀមរាប**

លេខ: ............៥១០...............មកប

**ជម្រាបមក**

**លោកនាយក ម៉េម៉រអង្គរ (ខេមបូឌា) (វិស័យទេសចរណ៍)**

អាសយដ្ឋាន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

**កម្មវត្ថុ ៖** ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

**យោង ៖** លិខិតលេខ ២១០៩១០៤៦៥៧ ចុះថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ម៉េម៉រអង្គរ (ខេមបូឌា)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៥៦នាក់ (ស្រី ៥៨នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ១៦០នាក់ (ស្រី៥៩នាក់) រយៈពេលចំនួន ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងនោះ៖

- កម្មករនិយោជិតចំនួន ១៤៣ នាក់ (ស្រី ៥៦ នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ ដុល្លារអាមេរិកក្នុងមួយខែ ។
- កម្មករនិយោជិតចំនួន ១៣ នាក់ (ស្រី ២ នាក់) មិនទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោកនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ)មុនថ្ងៃចូលធ្វើការ ហើយ **លោក** ត្រូវទទួលខុសត្រូវបង់ជួសកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់ទាំងនេះ។ ក្នុងករណីចាំបាច់ **លោក** អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់បានចំនួន ១លើក។ ករណីលើសពី១លើក **លោក** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សៀមរាប ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២១

**ត.ប. រដ្ឋមន្ត្រី**

**ជ. ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អនុប្រធានមន្ទីរ**

**ខន ម៉ុលីវ៉ាន**

**ចម្លងជូន:**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត